# ព័ត៌មានអំពីទីភ្នាក់ងាររដ្ឋាភិបាលនូវែលសេឡង់

ទីភ្នាក់ងាររដ្ឋាភិបាល ដែលបានរាយឈ្មោះខាងក្រោម គឺជាអង្គភាពទទួលខុសត្រូវចំពោះសន្តិសុខជាតិ និងការពារសិទ្ធិរបស់អ្នក នៅក្នុងប្រទេសនូវែលសេឡង់ ។ ព័ត៌មាននេះគឺប្រាប់អំពីអ្វីដែលជាភារកិច្ចរបស់ពួកគេ និងថាតើពួកគេ អាចជួយអ្នកដោយវិធីណា។ អ្នកអាចរាយការណ៍ បញ្ហាការជ្រៀតជ្រែកពីបរទេស ទៅកាន់ប៉ូលីសនូវែលសេឡង់ និង NZSIS ។ ដើម្បីស្វែងយល់បន្ថែមអំពីការរាយការណ៍ សូមមើល ៖ របៀបរាយការណ៍បញ្ហាការជ្រៀតជ្រែកពីបរទេស ។

NEW ZEALAND POLICE
Ngā Pirihimana o Aotearoa

ប៉ូលីសនូវែលសេឡង់ ផ្ដល់ជូនសេវា ជួយឲ្យពលរដ្ឋមានសុវត្ថិភាព និងមានអារម្មណ៍ថាមានសុវត្ថិភាពចំពោះការរស់នៅក្នុងផ្ទះរបស់ពួកគេ នៅតាមដងផ្លូវ និងនៅក្នុងសហគមន៍ ។ កងប៉ូលីសប្រតិបត្តិភារកិច្ច24ម៉ោងក្នុងមួយថ្ងៃយ៉ាងសកម្មក្នុងការកំណត់គោលដៅ និងទប់ស្កាត់បទល្មើស និងគ្រោះថ្នាក់ ។ ជាមួយនឹងកងកម្លាំង ប្រហែល 15,000 នាក់ ពួកយើងធ្វើការនៅស្ថានីយ៍ទីក្រុង និងជនបទ និងមជ្ឈមណ្ឌលប៉ូលីសដែលមានវិសាលភាពធំផេង ។

យើងប្រតិបត្តិការលើគោក លើទឹក និងលើអាកាស ហើយឆ្លើយតបចំពោះហេតុការណ៍ច្រើនជាង 1.3 លានដង ក្នុងមួយឆ្នាំ ឆ្លើយទូរសព្ទច្រើនជាង 925,000 ដង ដែលបានហៅមកលេខ 111 និងការហៅមកលេខដែលមិនមែនជាហេតុការណ៍អាសន្ន ចំនួន 743,000 ដង ។

កងកម្លាំងប៉ូលីស បានទទួលការហ្វឹកហាត់ ដើម្បីជួយ និងការពារមនុស្សគ្រប់រូប នៅក្នុងប្រទេសនូវែលសេឡង់ ។ សេវាផ្ដល់ជូនដោយក្រុមនគរបាល  ត្រូវបានផ្ដល់ជូនក្នុងស្មារតីគោរពសិទ្ធិមនុស្ស ហើយត្រូវបានផ្ដល់ជូនដោយឯករាជ្យ និងមិនលំអៀង ។

តួនាទីសំខាន់ៗរបស់ប៉ូលីស រួមមានការទប់ស្កាត់ ការស៊ើបអង្កេត ការដោះស្រាយ និងការកាត់បន្ថយឧក្រិដ្ឋកម្ម ក៏ដូចជាគ្រោះថ្នាក់ចរាចរណ៍ ផងដែរ ។ មុខងាររបស់កងនគរបាល មានជាអាទិ៍ ៖

- រក្សាសន្តិភាព
- រក្សាសុវត្ថិភាពសាធារណៈ
- ពង្រឹងច្បាប់
- ការទប់ស្កាត់ឧក្រិដ្ឋកម្ម
- ការគាំទ្រ និងផ្ដល់ទំនុកចិត្តដល់សហគមន៍
- សន្តិសុខជាតិ
- ការចូលរួមក្នុងសកម្មភាពសន្តិសុខ នៅក្រៅទឹកដីនូវែលសេឡង់
- ការគ្រប់គ្រងស្ថានភាពអាសន្ន ។

NEW ZEALAND POLICE
Ngā Pirihimana o Aotearoa

**មន្ត្រីទំនាក់ទំនងជនជាតិភាគតិច**
កងនគរបាល ឲ្យតម្លៃលើភាពចម្រុះជាតិសាសន៍ និងគាំទ្រសហគមន៍ជនជាតិភាគតិច ដោយមានមន្ត្រីទំនាក់ទំនងជនជាតិនៅទូទាំងប្រទេស ។ ពួកគេធ្វើការជាមួយសហគមន៍ដើម្បីជួយពួកគេឲ្យយល់ដឹង និងទទួលបានសេវាប៉ូលិស ផ្តល់ព័ត៌មានដល់ប៉ូលិសអំពីកង្វល់របស់សហគមន៍ និងធ្វើការជាមួយប៉ូលិសក្នុងការស៊ើបអង្កេត និងទប់ស្កាត់ឧក្រិដ្ឋកម្មដែលពាក់ព័ន្ធនឹងសហគមន៍ជនជាតិភាគតិច ។

កងកម្លាំងរបស់យើងខ្ញុំ តែងមានឆន្ទៈក្នុងការស្តាប់កង្វល់របស់អ្នក និងធ្វើការរួមគ្នាជាមួយអ្នកដើម្បីបង្កើនសុវត្ថិភាព ។

ប្រសិនបើមានការគំរាមកំហែងដល់អ្នក ដោយផ្ទាល់  ឬតាមអនឡាញ ដែលធ្វើឱ្យអ្នកភ័យខ្លាចចំពោះខ្លួនអ្នក ឬអ្នកដទៃ សូមទាក់ទងប៉ូលីស ។ ត្រង់នេះ គឺរួមបញ្ចូលទាំងឧប្បត្តិហេតុណាមួយដែលអាចកើតឡើង ដោយហេតុផលពូជសាសន៍ ជំនឿ ទំនោរផ្លូវភេទ អត្តសញ្ញាណយេនឌ័រ ពិការភាព ឬអាយុ ។

ប្រជាជននូវែលសេឡង់ទាំងអស់ ត្រូវដឹងអំពីស្ថានភាពជុំវិញខ្លួន ហើយរាយការណ៍សញ្ញាគួរឱ្យសង្ស័យ ឬសញ្ញាខុសប្រក្រតី ទៅអាជ្ញាធរ ។

**111 នគរបាលឆ្លើយតបគ្រាអាសន្ន ៖**
ទូរសព្ទទៅលេខ 111 ហើយសុំជំនួយពីប៉ូលិសនៅពេល ៖

- មានមនុស្សរងរបួស ឬគ្រោះថ្នាក់ ឬ
- មានហានិភ័យធ្ងន់ធ្ងរ ហានិភ័យភ្លាមៗ ឬមានហានិភ័យដោយគេចមិនផុតចំពោះអាយុជីវិតមនុស្ស ឬចំពោះទ្រព្យសម្បត្តិ  ឬឧក្រិដ្ឋកម្មកំពុងកើតមាន ឬទើបតែប្រព្រឹត្ត ហើយជនល្មើសស្ថិតនៅកន្លែងកើតហេតុនៅឡើយ ឬទើបតែចាកចេញពីកន្លែងកើតហេតុ ។

**105 រាយការណ៍ប៉ូលីសមិនមែនករណីបន្ទាន់ ៖**
ប្រសិនបើព័ត៌មាននោះ មិនបន្ទាន់ទេ ប្រជាពលរដ្ឋអាចរាយការណ៍អំពីសញ្ញាគួរឱ្យសង្ស័យ ឬសញ្ញាខុសប្រក្រតី ទៅកាន់ប៉ូលីសមូលដ្ឋាន ដោយ ៖

- បំពេញរបាយការណ៍តាមអនឡាញ នៅឯ 105.police.govt.nz ឬហៅទូរសព្ទទៅកាន់លេខមិនមែនសម្រាប់គ្រាអាសន្ន 105
- ចូលទៅកាន់ ស្ថានីយនគរបាលដែលនៅជិតបំផុត
- ហៅទៅ ក្រុមបញ្ឈប់ឧក្រិដ្ឋកម្ម តាមលេខ 0800 555 111

ប្រសិនបើអ្នកត្រូវការនិយាយជាមួយប៉ូលីស សូមទូរសព្ទទៅលេខ 105 ពីទូរសព្ទចល័ត ឬទូរសព្ទលើតុ ក្នុងប្រព័ន្ធណាក៏បានដែរ ។ នេះជាលេខផ្តល់សេវាទូទាំងប្រទេសដោយឥតគិតថ្លៃ ចំនួន 24/7 ។ ប្រសិនបើហៅ 105 មិនចូល សូមទាក់ទងមកយើងខ្ញុំតាមអនឡាញ តាមអាសយដ្ឋាន https://www.police.govt.nz/use-105 ។

**Te Pā Whakamarumaru**
New Zealand Security
Intelligence Service

New Zealand Security Intelligence Service (NZSIS) គឺជាទីភ្នាក់ងារស៊ើបការណ៍សន្តិសុខក្នុងស្រុករបស់ប្រទេសនូវែលសេឡង់ ។ បេសកកម្មរបស់អង្គភាពនេះ គឺដើម្បីរក្សាសុវត្ថិភាព និងសន្តិសុខដល់ប្រទេសនូវែលសេឡង់ និងពលរដ្ឋរបស់ខ្លួន ។

NZSIS គឺជានាយកដ្ឋានសេវាសាធារណៈ ដែលមានតួនាទីស៊ើបអង្កេតការគំរាមកំហែងដល់សន្តិសុខជាតិរបស់ប្រទេសនូវែលសេឡង់ ។ ត្រង់នេះគឺមានន័យថាការពារប្រទេស នូវែលសេឡង់ ជាសង្គមសេរី បើកចំហ និងប្រជាធិបតេយ្យ ។ អង្គភាពនេះ ក៏មានតួនាទីជួយការពារទំនាក់ទំនងអន្តរជាតិ និងសុខុមាលភាពសេដ្ឋកិច្ចរបស់ប្រទេស នូវែលសេឡង់ផងដែរ ។

អង្គភាពនេះ គឺជាទីភ្នាក់ងារសន្តិសុខក្នុងប្រទេសរបស់នូវែលសេឡង់ និងនាំមុខចំពោះកិច្ចការស៊ើបការណ៍សម្ងាត់ពីមនុស្ស ។ត្រង់នេះ មានន័យថា អង្គភាពនេះ មាន តួនាទីប្រមូលព័ត៌មាន ដោយការជួបនិយាយជាមួយមនុស្សផ្សេងៗគ្នា ។ ព័ត៌មានចារកម្ម ដែលប្រមូលបានដោយ NZSIS ត្រូវបញ្ជូនទៅរដ្ឋាភិបាល និងអ្នករៀបចំ គោលនយោបាយផ្សេងទៀត ដើម្បីគាំទ្រដល់ការ សម្រេចចិត្តត្រឹមត្រូវ ។

មុខងារមួយទៀតរបស់ NZSIS គឺជួយដល់ ភ្នាក់ងាររដ្ឋាភិបាល និងភ្នាក់ងារដទៃទៀត ដើម្បីការពារពលរដ្ឋ ព័ត៌មាន និងទ្រព្យសម្បត្តិរបស់ពួកគេពីការគំរាមកំហែងសន្តិសុខជាតិ ។

ចំណុចស្នូលនៃការងារសំខាន់ៗរបស់ NZSIS គឺ ៖

- ការជ្រៀតជ្រែកពីបរទេស រួមទាំងការកំណត់មុខព្រួញសហគមន៍ជនជាតិភាគតិច ដោយសកម្មភាពរដ្ឋបរទេសបង្ខិតបង្ខំ ។
- ចារកម្ម
- អំពើជ្រុលនិយម និងភេរវកម្ម

NZSIS ធ្វើការយ៉ាងជិតស្និទ្ធជាមួយដៃគូក្នុងប្រទេស ដូចជាប៉ូលីសនូវែលសេឡង់ និងការិយាល័យ សន្តិសុខទំនាក់ទំនងរដ្ឋាភិបាល (GCSB) ។ អង្គភាពនេះ ក៏ធ្វើការជាមួយសហគមន៍, iwi Māori, រដ្ឋាភិបាលក្នុងតំបន់, អង្គភាព បម្រើវិស័យអប់រំ, អង្គភាពអាជីវកម្ម និងអង្គការនានា ដែលជាផ្នែកនៃបេសកកម្មរបស់ខ្លួន ។

អង្គភាពនេះ ប្រតិបត្តិការ ក្រោមច្បាប់មួយហៅថា ច្បាប់ចារកម្ម និងសន្តិសុខ ឆ្នាំ 2017 ដែលធានាថា NZSIS អនុវត្តសកម្មភាពស្របតាមច្បាប់ មានអព្យាក្រឹតភាពផ្នែកនយោបាយ និងរក្សាកាតព្វកិច្ចសិទ្ធិមនុស្ស ។ NZSIS ត្រូវអនុវត្តសកម្មភាពការងារ ដោយអនុលោមតាមអាទិភាពផ្នែកចារកិច្ច ដែលបានកំណត់ដោយរដ្ឋាភិបាលនូវែលសេឡង់ ។

NZSIS មិនអាចចាប់ ឬឃុំខ្លួននរណាម្នាក់ឡើយ ហើយអង្គភាពនេះក៏ មិនអាចស៊ើបអង្កេត មនុស្សដោយ សារតែជំនឿ សញ្ជាតិរបស់ពួកគេ ឬដោយសារការចូលរួមក្នុងសកម្មភាពតវ៉ាស្របច្បាប់ ឡើយ ។

ដូចនាយកដ្ឋានសេវាសាធារណៈទាំងអស់ដែរ អង្គភាព NZSIS ត្រូវមានគណនេយ្យភាពចំពោះ សារការីសាធារណៈ, ស្នងការកិច្ចការឯកជនភាព, ការិយាល័យអគ្គសវនករ និងគណៈកម្មការសេវាសាធារណៈ ។

អង្គភាព NZSIS ក៏ជាកម្មវត្ថុនៃការត្រួតពិនិត្យឯករាជ្យ និងគ្រប់គ្រងជ្រោយ ពីអគ្គអធិការកិច្ចស៊ើបការណ៍ និងសន្តិសុខ ផងដែរ ។ តួនាទីរបស់អង្គភាពនេះ គឺស៊ើបអង្កេតពាក្យបណ្ដឹង និងធ្វើការស៊ើបអង្កេតអំពីភ្នាក់ងារស៊ើបការណ៍សម្ងាត់ ដើម្បីធានាថាពួកគេបំពេញភារកិច្ចស្របច្បាប់ និងត្រឹមត្រូវ ។ អង្គភាព NZSIS ក៏មានគណនេយ្យភាពចំពោះសភា និងរដ្ឋមន្ត្រីនៃប្រទេសនូវែលសេឡង់ផងដែរ ។

**ស្វែងយល់បន្ថែមនៅ** [Home | New Zealand Security Intelligence Service]
**ទទួលបានព័ត៌មាន** [Engagement | New Zealand Security Intelligence Service]
**រាយការណ៍ក្តីបារម្ភ** [Reporting a national security concern]

**Te Tira Tiaki**
Government Communications Security Bureau

ការិយាល័យសន្តិសុខទំនាក់ទំនងរដ្ឋាភិបាល (GCSB) គឺជាទីភ្នាក់ងារនាំមុខគេរបស់ប្រទេសនូ វែលសេឡង់ សម្រាប់ផ្តល់សញ្ញាស៊ើបការណ៍ ។ ត្រង់នេះគឺមានន័យថា ជាកាសម្ងាត់ ដែលបានទទួលពីការទំនាក់ទំនងតាម អេឡិចត្រូនិច ។

ព័ត៌មានចារកម្មនេះ ត្រូវផ្តល់ជូនភ្នាក់ងាររដ្ឋាភិបាល ដើម្បីគាំទ្រដល់ប្រតិបត្តិការ និងការសម្រេចចិត្ត របស់ពួកគេ ។ GCSB ក៏ទទួលបានព័ត៌មានចារកិច្ច ពីដៃគូក្រៅប្រទេស ជាពិសេសពីប្រទេសអូស្ត្រាលី សហរដ្ឋ អាមេរិក ចក្រភពអង់គ្លេស និងកាណាដា ផងដែរ ។ ការរួមបញ្ចូលគ្នានៃ GCSB និងព័ត៌មានចារកម្ម ពីក្រៅប្រទេស ជួយឲ្យប្រទេសនូវែលសេឡង់យល់បាន អំពីពិភពលោក និងគ្រប់គ្រងការគំរាមកំហែង សន្តិសុខជាតិ ។

GCSB ក៏ជាភ្នាក់ងារប្រតិបត្តិការនាំមុខគេផងដែរ ចំពោះ ការងារសន្តិសុខអនឡាញ តាមរយៈមជ្ឈមណ្ឌលជាតិសន្តិសុខអនឡាញ (NCSC) ដែលជាអង្គភាពការងារ ជំនាញមួយ នៅក្នុងអង្គភាព GCSB ។ អង្គភាព NCSC ជាអ្នកផ្តល់សេវាសន្តិសុខអនឡាញ ដល់ប្រទេស នូវែលសេឡង់ទាំងអស់ - គិតចាប់ពីកម្រិតបុគ្គល រហូត ដល់អាជីវកម្មខ្នាតតូច និងមធ្យម និងអង្គការ សហគ្រាស ធំៗ រដ្ឋាភិបាល និងអង្គការសំខាន់ៗថ្នាក់ជាតិ ។

Own Your Online គឺជាគេហទំព័ររបស់ NCSC ដែលផ្តោតលើការផ្តល់ដំបូន្មាន និងការណែនាំអំពីសន្តិសុខ អនឡាញ សម្រាប់បុគ្គល និងអាជីវកម្មខ្នាតតូច ទៅមធ្យម ។ ដើម្បីរាយការណ៍អំពីឧប្បត្តិហេតុសុវត្ថិភាព តាមអនឡាញ សូមចូលទៅកាន់ Own Your Online ឬ មជ្ឈមណ្ឌលសន្តិសុខអនឡាញជាតិ (National Cyber Security Center) ។

GCSB ធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គភាព សេវាចារកិច្ច សន្តិសុខនូវែលសេឡង់ (NZSIS) ។ អង្គភាព NZSIS ជាអ្នកស៊ើបអង្កេតការគំរាមកំហែងដល់សន្តិសុខជាតិ របស់ប្រទេសនូវែលសេឡង់ រួមទាំងកិច្ចការពារ លទ្ធិប្រជាធិបតេយ្យរបស់នូវែលសេឡង់ ការគំរាមកំហែងជ្រៀតជ្រែកពីបរទេស និងសិទ្ធិរបស់ មនុស្សទាំ ងអស់ក្នុងការរស់នៅ និងក្នុងការនិយាយស្តី ដោយសេរីភាព ។

មានការការពារជាច្រើនសម្រាប់ធានាថា អង្គភាព GCSB អនុវត្តសកម្មភាពការងារ ដោយអនុលោម តាមច្បាប់ប្រទេសនូវែលសេឡង់ និងកាតព្វកិច្ច សិទ្ធិមនុស្ស ។

អង្គភាព GCSB បំពេញតួនាទីរបស់ខ្លួន ក្រោមច្បាប់ចារកិច្ច និងសន្តិសុខឆ្នាំ 2017 ដែលជាច្បាប់សម្រាប់ ការពារប្រទេសនូវែលសេឡង់ ជាសង្គមសេរី បើកចំហ និងប្រជាធិបតេយ្យ ។

អង្គភាព GCSB គឺជានាយកដ្ឋានសេវាសាធារណៈ ហើយដូចភ្នាក់ងាររដ្ឋាភិបាលទាំងអស់ដែរ គឺត្រូវមាន គណនេយ្យភាពចំពោះសាការីសាធារណៈ ស្នងការ ឯកជនភាព ការិយាល័យនៃអគ្គសវនករ និងគណៈកម្មការសេវាសាធារណៈ ។ GCSB ក៏ជាកម្មវត្ថុ នៃការត្រួតពិនិត្យយ៉ាងតឹងរឹង ដោយឯករាជ្យ និងពេញលេញ ពីសំណាក់អគ្គស្នងការ អធិការកិច្ច ស៊ើបការណ៍សម្ងាត់ និងសន្តិសុខផងដែរ ។ អគ្គស្នងការអធិការកិច្ចស៊ើបអង្កេតលើបណ្តឹង ប្រឆាំងនឹងភ្នាក់ងារស៊ើបការណ៍ ហើយធ្វើការ ត្រួតពិនិត្យ និងសាកសួរ ដើម្បីពិនិត្យមើលថា តើអង្គភាពនេះ អនុវត្តសកម្មភាពស្របច្បាប់ និង ត្រឹមត្រូវ ។ GCSB ក៏មានគណនេយ្យភាពចំពោះសភា និងរដ្ឋមន្ត្រីនៃប្រទេសនូវែលសេឡង់ផងដែរ ។

បុគ្គលិកប្រហែល 600 នាក់ធ្វើការឱ្យអង្គភាព GCSB ។ បុគ្គលិកទាំងនោះ មានប្រភពចេញពីសង្គមទាំងមូល របស់ប្រទេសនូវែលសេឡង់ ហើយបំពេញតួនាទី ផ្សេងៗគ្នា ។ អង្គភាព GCSB មានគេហទំព័រសាធារណៈរបស់ខ្លួននៅឯ www.gcsb.govt.nz ដែលមានពន្យល់បន្ថែម អំពីការងាររបស់ខ្លួន ។

Te Kāhui Tika Tangata
Human Rights Commission

គណៈកម្មាធិការសិទ្ធិមនុស្ស Te Kāhui Tika Tangata គឺជាស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិរបស់ប្រទេសនូវែលសេឡង់ (NHRI) ។ “He whakamana tangata ។ ជីវិតនៃសេចក្តីថ្លៃថ្នូរសម្រាប់ទាំងអស់គ្នា” គឺជាបាវចនារបស់យើង ហើយយើងធ្វើឲ្យវាមានន័យពិតប្រាកដ ដោយការការពារ និងពង្រឹងសិទ្ធិមនុស្សរបស់ប្រជាជននូវែលសេឡង់ទាំងអស់ និងធានាថា Te Tiriti o Waitangi ត្រូវបានបង្កប់នៅក្នុងកិច្ចការគ្រប់យ៉ាងដែលយើងធ្វើ ។

គណៈកម្មការសិទ្ធិមនុស្ស មានស្នងការចំនួនបួន ដែលជាដៃគូអភិបាលកិច្ចសិទ្ធិជនជាតិដើមភាគតិច និងមានបុគ្គលិកប្រហែល 60 នាក់ ធ្វើការនៅឯ Auckland, Wellington និង Christchurch ។

យើងលើកកម្ពស់ និងការពារសិទ្ធិមនុស្ស តាមមធ្យោបាយច្រើនយ៉ាង ។ មធ្យោបាយមួយក្នុងចំណោមមធ្យោបាយទាំងនេះគឺ តាមរយៈសេវាឥតគិតថ្លៃ និងសម្ងាត់របស់យើងខ្ញុំ ក្នុងការជួយសាធារណជនដោះស្រាយបណ្តឹងអំពីការរើសអើងដោយខុសច្បាប់ ក្រោមច្បាប់សិទ្ធិមនុស្សឆ្នាំ 1993 ។

ទីប្រឹក្សាសំណុំរឿង និងអ្នកសម្របសម្រួលរបស់យើងធ្វើការជាមួយពលរដ្ឋដើម្បីផ្តល់ព័ត៌មាន គាំទ្រការរកដំណោះស្រាយទាន់ពេលវេលា និងផ្តល់សេវាដោះស្រាយវិវាទ ។ សេវាកម្មរបស់យើង គឺផ្តល់ជូនដោយឥតគិតថ្លៃ និងជាការសម្ងាត់ ។ យើងមិនស៊ើបអង្កេតបណ្តឹង ឬកំណត់ថាតើមានការរំលោភច្បាប់ដែរឬទេ។

អ្នកអាចដាក់ពាក្យប្តឹងបាន ប្រសិនបើអ្នកគិតថាអ្នកបានជួបប្រទះការរើសអើងដោយសារពូជសាសន៍ សាសនា ភេទ ការបង្ហាញអត្តសញ្ញាណយេនឌ័រ ទំនោរផ្លូវភេទ ពិការភាព ឬលក្ខណៈផ្ទាល់ខ្លួនផ្សេងទៀត ។

អ្នកក៏អាចប្តឹងបានដែរ ប្រសិនបើអ្នកបានជួបប្រទះការបៀតបៀនផ្លូវភេទ អាកប្បកិរិយាផ្លូវភេទដែលអ្នកមិនព្រមទទួល ឬប្រសិនបើមាននរណាម្នាក់កំពុងព្យាយាមផ្លាស់ប្តូរទំនោរផ្លូវភេទ ឬការបង្ហាញអត្តសញ្ញាណយេនឌ័ររបស់អ្នក ។

អំពើរើសអើងអាចកើតចេញពីបុគ្គល ដូចជានិយោជកម្ចាស់ហាង គ្រូបង្រៀន ឬកើតចេញពីអង្គការ ឬសេវាដូចជាភោជនីយដ្ឋាន ឬអង្គការរដ្ឋាភិបាល ។

ការដាក់ពាក្យបណ្តឹងទៅកាន់គណៈកម្មាធិការសិទ្ធិមនុស្ស គឺមិនអស់ប្រាក់ឡើយ ហើយជាការសម្ងាត់ទៀតផង ។ ដើម្បីស្វែងយល់បន្ថែមអំពីការដាក់ពាក្យបណ្តឹង សូមចូលមើលព័ត៌មានក្នុងគេហទំព័ររបស់យើង តាមអាសយដ្ឋាន tikatangata.org.nz ។

ព័ត៌មានមានជាភាសា តេរេអូម៉ាអូរី សាម័រ តុងហ្គាន ចិនបុរាណ ចិនសាមញ្ញ និងហិណ្ឌូ ក៏ដូចជាទម្រង់ដែលអាចមើលបាន ដូចជាទម្រង់ ងាយស្រួលអាន (Easy Read) ឯកសារអក្សរស្ទាប ការបោះពុម្ពអក្សរធំៗ និងជាសំឡេង ។

He whakamana tangata.
ជីវិតថ្លៃថ្នូរសម្រាប់ទាំងអស់គ្នា។

Ombudsman

Tuia kia ōrite · Fairness for all

សាការីសាធារណៈ អាចជួយបាន នៅពេលដែលពលរដ្ឋ មានបញ្ហាជាមួយភ្នាក់ងាររដ្ឋាភិបាល រួមទាំងរដ្ឋាភិបាលកណ្ដាល និងរដ្ឋាភិបាលមូលដ្ឋាន ។ ឧទាហរណ៍ ក្រសួងអភិវឌ្ឍន៍សង្គម ក្រសួងអន្តោប្រវេសន៍នូវែលសេឡង់ សាលារៀនរបស់កូនអ្នក និងក្រុមប្រឹក្សាប្រចាំមូលដ្ឋានរបស់អ្នក ។

ការសាកសួរព័ត៌មាន ឬការដាក់បណ្ដឹងទៅកាន់ការិយាល័យសាការីសាធារណៈ  គឺមិនគិតថ្លៃ ហើយនរណាក៏អាចដាក់បានដែរ ។

អ្នកអាចដាក់ពាក្យបណ្ដឹងទៅកាន់សាការីសាធារណៈបាន ប្រសិនបើអ្នកជឿថា ភ្នាក់ងាររដ្ឋាភិបាលបានធ្វើសកម្មភាព ឬធ្វើការសម្រេចចិត្តដែលអ្នកមិនពេញចិត្ត ដែលអ្នកយល់ឃើញថា មិនយុត្តិធម៌ មិនសមហេតុផល ឬខុស ។ ពាក្យបណ្ដឹងរបស់អ្នកនឹងត្រូវយកទៅពិចារណាយ៉ាងប្រុងប្រយ័ត្ន ។ សាការីសាធារណៈ អាចសុំឱ្យអ្នកប្ដឹងទៅកាន់ទីភ្នាក់ងារនោះជាមុនសិន ហើយគេអាចផ្ដល់ដំបូន្មានដល់អ្នក អំពីរបៀបដាក់ពាក្យបណ្ដឹងបែបនេះ ។ សាការីសាធារណៈ អាចប្រាប់អ្នកអំពីវិធីផ្សេងទៀតដែលអ្នកអាចលើកឡើងពីកង្វល់របស់អ្នក ។ សាការីសាធារណៈ ក៏អាចជួយដោះស្រាយបណ្ដឹងរបស់អ្នក ឬស៊ើបអង្កេតសាច់រឿងក្នុងបណ្ដឹងរបស់អ្នកបានផងដែរ ។

អ្នកក៏អាចប្ដឹងទៅកាន់សាការីសាធារណៈឲ្យជួយដោះស្រាយផងដែរ ប្រសិនបើទីភ្នាក់ងាររដ្ឋាភិបាលបដិសេធមិនផ្ដល់ព័ត៌មានដល់អ្នក ។

សាការីសាធារណៈ ក៏អាចជួយបុគ្គលណាដែលមានបំណងចង់បង្ហាញអំពីកំហុសធ្ងន់ធ្ងរ ដែលបានកើតឡើងនៅកន្លែងធ្វើការរបស់ពួកគេ ឬអ្នកដែលត្រូវការដំបូន្មានអំពីរបៀបដែលពួកគេនឹងទទួលបានកិច្ចការពារ រនៅពេលធ្វើការលាតត្រដាង រឿងរ៉ាវបែបនេះ ផងដែរ ។ សាការីសាធារណៈ អាចស៊ើបអង្កេតរឿងរ៉ាវដែលមានការលាតត្រដាង ឬបញ្ជូនបណ្ដឹងទាំងនោះ ទៅកាន់ 'អាជ្ញាធរសមស្រប' ដើម្បីចាត់វិធានការណ៍ ។

អ្នកនឹងមិនមានបញ្ហាអ្វីឡើយ ចំពោះការទាក់ទងសាការីសាធារណៈ ។ សាការីសាធារណៈ មិនត្រូវយកកង្វល់របស់អ្នក ទៅប្រាប់ឲ្យអ្នកដទៃដឹងឡើយ លើកលែងតែការធ្វើបែបនេះចាំបាច់សម្រាប់ជួយដោះស្រាយបញ្ហានោះ ។

សាការីសាធារណៈ គឺឯករាជ្យ ហើយមិនផ្ដល់ដំបូន្មានផ្នែកច្បាប់ ឬដើរតួជាអ្នកតស៊ូមតិ ឬភ្នាក់ងារ ឡើយ ។

**ការទំនាក់ទំនង**

អ្នកអាចទាក់ទងសាការីសាធារណៈ ប្រសិនបើអ្នកមានសំណួរ ឬចង់ដាក់ពាក្យបណ្ដឹង ។

- **លេខទូរស័ព្ទហៅមិនអស់ប្រាក់ ៖ 0800 802 602**
- **អនឡាញ តាមរយៈទម្រង់បែបបទដាក់ពាក្យបណ្ដឹង នៅលើគេហទំព័ររបស់សាការីសាធារណៈ** នៅអាសយដ្ឋាន ៖ https://www.ombudsman.parliament.nz/ ហើយចុច 'ទទួលបានជំនួយ (សម្រាប់សាធារណៈជន)'
- **អ៊ីម៉េល ៖ info@ombudsman.parliament.nz**
- **ប្រអប់ប្រៃសនីយ៍ ៖ The Ombudsman, PO Box 10152, Wellington 6143**

ធនធាននានាដែលមានប្រយោជន៍ និងឯកសារបោះពុម្ពផ្សាយជាភាសា និងទម្រង់ផ្សេងៗ មាននៅលើគេហទំព័រសាការីសាធារណៈ ។